# ការសំភាសន៍របស់លោកតា គង់ ឆាយ

ក៖ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍ គង់ឆាយ

## <u>ការសង្ខេបប្រវត្តិរបស់ លោកតា គង់ ឆាយ</u>

លោកតា គង់ ឆាយ មានអាយុ70ឆ្នាំ នៅក្នុងឆ្នាំ2018។លោកតា គង់ ឆាយ មានភេទប្រុស លោកតា គង់ ឆាយ មានទីលំនៅបច្ចុប្បន្ននៅ ភូមិទួល ឃុំមហាសាង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

ក៖ ចឹងជាដំបូងខ្ញុំអរគុណតាដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់តា ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍តា ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយតា ចឹងដោយសារតែវេបសាយដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់តាយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ដែរបានពិភាក្សាជាមួយតាទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីអោយទុកអោយកូនចៅបានស្ដាប់ដែរទេតា?

ខ៖ អត់អីទេបើសិនជាចង់សំភាសន៍ សំភាសន៍ទៅមានទាស់ខុសអី

ក៖ បាទតាបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍តាខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍តាគឺនៅថ្ងៃទី10ខែ4 ឆ្នាំ2018 ធ្វើនៅភូមិមហាសាងមែនទេតា?

ខ៖ នៅភូមិទួល

ក៖ នៅភូមិទួល ចុះឃុំអីគេដែរទៅតា?

ខ៖ នៅឃុំមហាសាង

កៈ  ឃុំមហាសាង នៅស្រុកអីទៅ?

ខៈ  នៅស្រុកភ្នំស្រួច

កៈ  នៅស្រុកកំពង់ស្រួច នៅខេត្តកំពង់ស្ពឺយើង?

ខៈ  នឹងហើយនៅខេត្តកំពង់ស្ពឺ

កៈ  បាទតា ចុះសំរាប់តាមានឈ្មោះពេញរបស់តានឹងមានឈ្មោះអីគេដែរទៅតា?

ខៈ  ឈ្មោះពេញរបស់ខ្ញុំនឹងមានឈ្មោះគង់ ឆាយ

កៈ  ប៉ុន្តែមានឈ្មោះហៅក្រៅអត់តា?

ខៈ  អត់ដែរមានទេ

កៈ  ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះតាអីផ្សេងទេ?

ខៈ  កាលពីនៅក្មេងនៅសម័យឆ្នាំ1970 រហូតមកទល់នឹងឆ្នាំ1975នឹងខ្ញុំមានឈ្មោះព្រំសារឿន

កៈ  អូ៎!!ចឹងមានន័យថាតាមានឈ្មោះពីរហោសតា?

ខៈ  កាលពីខ្ញុំនៅធ្វើជាទាហ៊ាននឹង

កៈ  ចុះកាលតានៅឈ្មោះព្រំសា រឿននឹង ទាហ៊ានជាអ្នកដាក់អោយមែនទេតា?

ខៈ  បាទកាលពីខ្ញុំនៅធ្វើទាហ៊ាននឹង

កៈ  ប៉ុន្តែឈ្មោះតាឥឡូវនឹងឈ្មោះអោយត្រូវក្នុងបញ្ជីជាតិតែម្តងនឹងមានឈ្មោះអីគេដែរតា?

ខៈ  មានឈ្មោះគង់ ឆាយ

កៈ  អូ៎!!ចឹងមានន័យថាយើងមានឈ្មោះពីរតែម្តងនឹងហោសតា?

ខៈ  បាទ កាលពីសម័យយើងកាលពីឆ្នាំ1970នឹងខ្ញុំដាក់ឈ្មោះខ្ញុំនឹងព្រំសា រឿន

កៈ  បាទតា ចុះតាសព្វថ្ងៃនឹងតាអាយុប៉ុន្មានដែរតា?

ខៈ  សព្វថ្ងៃនឹងអាយុចូល70ឆ្នាំហើយនឹង

ក៖  ចឹងតាអាយុ70ឆ្នាំណតា ចុះតាកើតនៅថ្ងៃខែឆ្នាំណាដែរតាចងចាំទេ?

ខ៖  នៅក្នុងឆ្នាំ1948

ក៖  នៅក្នុងឆ្នាំ1948 ចុះថ្ងៃខែតាមានចងចាំទេ?

ខ៖  នៅថ្ងៃទី25 នឹងខែ5

ក៖  ថ្ងៃទី25 ខែ5ណតា
ចុះតាមានចងចាំថាតាកើតនៅច័ន្ទគតិហាសតាឆ្នាំអីគេដែរលក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖  ខ្ញុំកើតនៅឆ្នាំឆ្លូវ

ក៖  អូ៎!!ចុះសំរាប់តាកើតនៅណាដែរតា?

ខ៖  ខ្ញុំកើតនៅភូមិទូល

ក៖  នៅភូមិទូល ឃុំមហាសាង?

ខ៖  ភូមិទូល ឃុំមហាសាង

ក៖  នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ?

ខ៖  នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺយើងនឹងហាស

ក៖  ចុះសំរាប់តាមានបងប្អូនចំនួនប៉ុន្មាននាក់ដែរតា?

ខ៖  ខ្ញុំមានបងប្អូនចំនួន6នាក់នឹង

ក៖  ចុះតាជាកូនទីប៉ុន្មានដែរតា?

ខ៖  ខ្ញុំជាកូនទី3

ក៖  ចុះមានស្រីប៉ុន្មាននាក់ ហើយនឹងប្រុសប៉ុន្មាននាក់ដែរតា?

ខ៖  នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំនឹងមានស្រី3នាក់ នឹងប្រុស3នាក់នឹង

ក៖  អូ៎!!ចុះសំរាប់ពួកគាត់នៅរស់ទាំងអស់ដែរតើហីតា?

ខ៖  ពួកគាត់ស្លាប់បាត់អស់ហើយនឹងសព្វថ្ងៃនឹងនៅតែ3នាក់ទេនឹង បងគេបង្អស់នឹងមួយ មើលនៅខ្ញុំបន្ទាប់ពីបងទី2

ក៖  បាទតាបាទនឹង?

ខ៖  ហើយចឹងនៅប្អូនមួយទៀតបន្ទាប់ប្អូនទី4នឹង

ក៖  អូ៎!!ចឹងប៉ុន្តែ?

ខ៖  ចឹងនៅ3នាក់នៅរាល់ថ្ងៃនេះនឹង

ក៖  ប៉ុន្តែតាមានចងចាំឈ្មោះបងប្អូនរបស់តាទាំងអស់ដែរទេ?

ខ៖  ចាំបងប្អូនទាំងអស់នឹងចងចាំដែរនឹង

ក៖  ទាំងអស់អ្នកស្លាប់ទាំងអស់អ្នកនៅរស់ហាស?

ខ៖  បាទ!!ចងចាំដែរនឹង

ក៖  ចុះពួកគាត់មានឈ្មោះអីគេខ្លះដែរទៅតា?

ខ៖  អ្នកស្លាប់នឹងមានឈ្មោះគង់ ឡាញ់ មួយ

ក៖  នឹងបងគេហីតា?

ខ៖  ឈ្មោះគង់ ឡាញ់នឹងបន្ទាប់បងគាត់ជាកូនទី2នឹង

ក៖  ប៉ុន្តែបងគេនឹងមានឈ្មោះអីគេដែរទៅតា?

ខ៖  បងគេនឹងមានឈ្មោះគង់ ណោវ

ក៖  អូ៎!!ប៉ុន្តែគាត់នៅរស់ទេ?

ខ៖  គាត់នៅរស់នឹងហាស

ក៖  អូ៎!!ប៉ុន្តែទី3នឹងមានឈ្មោះអីគេដែរតា?

ខ៖  ទី3នឹងរូបខ្ញុំនឹងផ្ទាល់នឹងហាស

ក៖  ចុះទី4វិញតា?

ខ៖ ទី4នឹងមានឈ្មោះគង់ ឆឹម

ក៖ ចុះទី5វិតាមានឈ្មោះអី?

ខ៖ ទី5នឹងមានឈ្មោះគង់ ណាន

ក៖ ចុះពៅគេនឹងមានឈ្មោះអីគេដែរតា?

ខ៖ ពៅគេនឹងមានឈ្មោះគង់ ណយ

ក៖ ចុះតាមានអនុស្សាវរីយ៍អីកាលពីតានៅក្មេងៗហាស
តើតាធ្លាប់បានលេងអីគេដែរជាមួយពយកគាត់ដែរទេ?

ខ៖ លេងជាមួយពួកណាដែរទៅ?

ក៖ លេងជាមួយបងប្អូនរបស់តាហាស ដូចជាធ្លាប់លេងឡឹកបាយឡ
លេងបិទពួនអីចឹងហាសធ្លាប់មានលេងអីទេ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងកាលពីជំនាន់ម្ដាយរបស់ខ្ញុំនឹងមានធុរះចឹងហាស
ការលេងសើចនឹងមិនសូវជាបាន លេងជាមួយប្អូនអីច្រើនទេ
ពីព្រោះតែប្អូនៗវានៅតូចៗ ចឹងយើងដើររកដើម្បីចិញ្ចឹមតែប្អូននឹងហាស

ក៖ អូ!!បាទតានឹង?

ខ៖ ហើយយើងធំជាងគេនឹង យើងបន្ទាប់ពីបងនឹង

ក៖ ប៉ុន្តែយើងធ្លាប់ទៅធ្វើស្រែបន្ទាប់ពីបងប្អូនដែរតើហីតា?

ខ៖ បាទធ្លាប់ទៅធ្វើការងារអីជាមួយបងប្អូនហើយម៉ែឪដូចថាគាត់អ្នកមិនសូវ

ក៖ មិនសូវធូរធារអីនឹងគេហោសតា?

ខ៖ គាត់មិនសូវជាអ្នកមានបានអីនឹងគេចឹងហាស
ហើយទទួលម្ដាយរបស់ខ្ញុំឈឺតាំងពីខ្ញុំនៅតូចមកនឹង

ក៖ ប៉ុន្តែឪពុកម្ដាយរបស់តាបានស្លាប់អស់ហើយរឺមួយក៏នៅដែរតា?

ខ៖ ឪពុកម្ដាយរបស់ខ្ញុំនឹងបានស្លាប់អស់ហើយ នៅសម័យពលពត

កៈ អូ៎!! ចុះតាគិតថាបងប្អូនរបស់តាដែរនៅរស់នឹងសព្វថ្ងៃគាត់នៅណាដែរតា?

ខៈ នៅក្នុងភូមិនឹងជាមួយគ្នាទាំងអស់គ្នានឹង

កៈ នៅទាំងអស់គ្នាតែម្តងនឹងហោសតា?

ខៈ បាទនឹងហើយ

កៈ អូ៎!!ប៉ុន្តែគាត់បានធ្វើអីគេខ្លះដែរទៅតា?

ខៈ រាល់ថ្ងៃនឹងគាត់ជាកសិករធ្វើស្រែធ្វើចំការនឹង ធម្មតានឹងអត់មានការងារអីទេ

កៈ អូ៎!!បាទតា?

ខៈ គ្មានធ្វើអីគេទេនឹង

កៈ ចុះសំរាប់ឪពុករបស់តានឹងមានឈ្មោះអីគេដែរតា?

ខៈ ឪពុករបស់ខ្ញុំនឹងមានឈ្មោះទូច គង់

កៈ គាត់មានឈ្មោះទូច គង់
បើនិយាយប្រៀបធៀបសព្វថ្ងៃនឹងគាត់ប្រហែលជាអាប៉ុន្មានដែរតា?

ខៈ អូ៎!!ឪពុករបស់ខ្ញុំនឹងបើគិតជាសព្វថ្ងៃនឹងអាយុគាត់ប្រហែលជា100ឆ្នាំជាងហើយនឹង

កៈ អូ៎!!អាយុ100ឆ្នាំជាងប៉ុន្តែតាមានដឹងថាគាត់កើតនៅណាដែរទេ?

ខៈ គាត់កើតនៅភូមិទួលដែរនឹង

កៈ ចុះយាយវិញតា?

ខៈ យាយក៏គាត់កើតនៅភូមិទួលដែរ

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរតា?

ខៈ ម្តាយរបស់ខ្ញុំនឹងមានឈ្មោះស្វាយ សៅ

កៈ ប៉ុន្តែយាយប្អូនតាប៉ុន្មានឆ្នាំដែរទៅ?

ខៈ អត់ខ្ញុំអត់សូវចងចាំដែរអានឹងហើយប្រហែលជា

កៈ ចុះតាកាលពីគាត់នៅរស់ឪពុករបស់តាហាស គាត់ធ្វើអីគេសំរាប់ចិញ្ចឹមដែរតា?

ខៈ គាត់កាលពីខ្ញុំនៅតូចៗនឹងគឺគាត់ជាគេហៅគណៈកម្មការភូមិដែរនឹង
ដូចខ្ញុំសព្វថ្ងៃនឹងចឹងដែរនឹង

កៈ បាទតាបាទ?

ខៈ នឹងហើយគាត់នៅគ្រប់គ្រងប្រជាពលរដ្ឋនៅក្នុងភូមិ
តាំងពីដើមចឹងមកគាត់អ្នកគ្រប់គ្រងក្នុងភូមិនឹង
ហើយគាត់ក៏ជាអ្នកមានមុខមានមាត់ចុះជំនាន់ណុងគាត់

កៈ អាចថាគាត់ជាអ្នកមានមុខមានមាត់ម្នាក់ក្នុងស្រុកនឹងដែរណេតា?

ខៈ បាទៗ!!នឹងហើយចឹងគាត់ជាអ្នកមានមុខមានមាត់គាត់គ្រប់គ្រងប្រជាពលរដ្ឋ
ដូចខ្ញុំរាល់ថ្ងៃចឹងដែរនឹង

កៈ បាទតា តាជាមេភូមិហីតា?

ខៈ កាលណុងគេហៅគណៈកម្មការភូមិនឹងហើយជាមេភូមិនឹងហើយ

កៈ បាទតាបាទនឹង?

ខៈ យើងនិយាយទៅជាមេភូមិនឹង

កៈ បាទតា ប៉ុន្តែតា?

ខៈ
ប៉ុន្តែគ្រាន់តែមេភូមិជំនាន់គាត់នឹងដូចថាគាត់មានសិទ្ធិជាងយើងសម័យឥឡូវនឹងហាស

កៈ បាទតាបាទ?

ខៈ នឹងសំរាប់ប្រជាពលរដ្ឋនឹង

កៈ ចុះសំរាប់ឪពុករបស់តាគាត់ស្លូតរឺមួយក៏កាចដែរតា?

ខៈ បាទថាម៉េច?

កៈ ឪពុករបស់តាគាត់ស្លូតរឺមួយក៏កាចដែរតា?

ខ៖ ឪពុករបស់ខ្ញុំនឹងគាត់ជាអ្នកស្លូតដែរទេ គាត់មិនមែនជាអ្នកកាចអីទេ

ក៖ ចុះម្តាយរបស់តាវិញ?

ខ៖ ប៉ុន្តែគ្រាន់តែគេខ្លាចគាត់

ក៖ អូ៎!!គេខ្លាចគាត់ហោសតា?

ខ៖

បាទ!!គាត់អ្នកស្លូតដែរទេប៉ុន្តែអ្នកលេងតែគាត់ហានិយាយនឹងដឹងតែខ្លាចគាត់ហើយនឹង

ក៖ អូ៎!!ចឹងហោសតា ចុះយាយជាមនុស្សបែបណាដែរទៅ?

ខ៖ យាយគាត់មនុស្សសាមញ្ញធម្មតានឹងហាស

ក៖ ប៉ុន្តែគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរតា?

ខ៖ គាត់ធ្វើតែស្រែ គាត់រកស៊ីធ្វើតែស្រែនឹងធ្វើចំការនឹង

ក៖ អូ៎!!បាទតាបាទ?

ខ៖ ពីដើមគេមានធ្វើអី

ក៖ បាទតាបាទនឹង?

ខ៖ គេគ្មានធ្វើអីទេហួសពីស្រែចំការនឹងជាមេផ្ទះមើលកូនចៅនឹង

ក៖ បាទតា ចុះឪពុករបស់តាគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅតាដែរទេ?

ខ៖ គាត់អត់ដែរនិយាយប្រាប់យើងដែរប៉ុន្តែគ្រាន់តែយើងដឹងថាប្រវត្តិរបស់គាត់នឹងក៏ជា

ក៖ កូនអ្នកកសិករ?

ខ៖ កសិករ នឹងកម្មករដែរ

ក៖ អូ៎!!ចុះយាយវិញគាត់មានធ្លាប់ប្រាប់ដែរទេតា?

ខ៖ យាយក៏ខ្ញុំដឹងថាគាត់ជាកូនកសិករធ្វើស្រែធ្វើចំការដូចតែយើងពីដើម
នឹងដូចអ្វីដែរយើងឥឡូវនឹងណាស់

កៈ បាទតាបាទ?

ខៈ ចុះមានអីរក

កៈ ចុះសំរាប់យាយតាខាងឪពុកនឹងតាមានស្គាល់ឈ្មោះគាត់ដែរទេ
យាយតាខាងឪពុករបស់តាហាស?

ខៈ យាយតាខាងឪពុកនឹងខ្ញុំអត់ចងចាំអស់ទេ ខ្ញុំអត់ចងចាំទេ

កៈ អូ្ន!!ឈ្មោះគាត់ក៏អត់ចងចាំដែរ?

ខៈ ខ្ញុំស្គាល់ឈ្មោះគាត់តានឹងឈ្មោះតាតូចៗនឹងខ្ញុំចងចាំ

កៈ ប៉ុន្តែយាយអត់មានចងចាំទេ?

ខៈ យាយនឹងអត់មានចងចាំទេ

កៈ ចុះយាយតាខាងម្តាយវិញតា?

ខៈ យាយតាខាងម្តាយវិញនឹងខ្ញុំស្គាល់នឹង

កៈ គាត់មានឈ្មោះអីគេដែរទៅ?

ខៈ គាត់មានឈ្មោះតាស្វាយ នឹងយាយចិន

កៈ អូ្ន!!ប៉ុន្តែយាយតាខាងម្តាយនឹងយាយតាខាងឪពុកនឹងតាមានដឹងដែរទេ?

ខៈ គាត់យាយតារបស់ខ្ញុំនឹងគាត់កើតនៅយើងខាងឃុំយ័មតាអ

កៈ ប៉ុន្តែនឹងខាងឪពុករឺមួយខាងម្តាយដែរតា?

ខៈ អានឹងខាងជីតា

កៈ ចុះខាងម្តាយវិញតាខាងយាយ?

ខៈ ខាងម្តាយនឹងនៅខាងស្រុកយើងនឹង

កៈ អូ្ន!!បាទតា ចុះសំរាប់តាដូចជាតានៅនឹងយូរនៅតា ដូចជានៅភូមិនឹងយូរនៅ?

ខៈ ខ្ញុំនៅនឹងតាំងពីកំណើតមកនឹង

កៈ អូ៎!!ចឹងវាប្រហែលជាចូលតាអាយុប៉ុន្មានដែរហើយតា?

ខៈ ឥឡូវនឹងវាចូលអាយុ70ឆ្នាំ

កៈ ចូលចិតជាហើយចឹងណាតា?

ខៈ អើរវាចូលចិតជាងហើយនឹង

កៈ ចុះតាមានបងបរឺមួយក៏សាច់ញ្ញាតិណាដែរទៅរស់នៅលក្រៅប្រទេសទេតា?

ខៈ អត់មានដែរអូន

កៈ នៅថៃ វៀតណាមអីអត់មានអ្នកធ្វើការណាហីតា?

ខៈ មានតែបងប្អូនជីដូនមួយអីនឹងមានខ្លះ

កៈ ចុះគាត់នៅណាដែរទៅតា?

ខៈ គាត់អ្នកខ្លះនៅដូចស្រុកគេឥឡូវនឹងគាត់ច្រើនតែទៅរកស៊ីគេនៅថៃ
នៅអីទៅមកៗនឹងហាស

កៈ អូ៎!!បាទតាចុះសំរាប់ភរិយារបស់តានឹងមានឈ្មោះអីគេដែរទៅតា?

ខៈ មានឈ្មោះទុយ សឹម

កៈ ប៉ុន្តែតាមានចងចាំគាត់ ថាបានរៀបអាពាហ៍ពិពាហ៍ជាមួយយាយពីឆ្នាំណាដែរទេ?

ខៈ នៅក្នុងឆ្នាំ1971នឹង

កៈ នៅក្នុងឆ្នាំ1971 ចុះថ្ងៃខែតាមានចងចាំទេ?

ខៈ អត់មានចងចាំទេអត់ចាំអស់ទេប៉ុន្តែគ្រាន់តែដឹងថានៅឆ្នាំ1971

កៈ បាទតា ចឹងសំរាប់តារៀបអាពាហ៍ពិពាហ៍ជាមួយយាយនឹងដូចជាតាជាអ្នករៀបចំ
រឺមួយឪពុកម្តាយជាអ្នករៀបចំអោយដែរតា?

ខៈ តាមឪពុកម្តាយនឹងហាស

កៈ អូ៎!!បាទប៉ុន្តែពេលណុងមានជាជំនូនអត់តា?

ខ៖ មានដែរនឹង

ក៖ ប៉ុន្តែពេលណុងមានច្រើនដែរទេតា?

ខ៖ មានជាជំនូនមាននេះធម្មតា ដូចយើងទៅស្ដីដណ្ដឹងគេធម្មតានឹងហាស

ក៖ ប៉ុន្តែដូចជាច្រើនដែរទេតា?

ខ៖ វាធម្មតានឹងអត់មានច្រើនហើយក៏អត់មានតិចដែរនឹង ចុះយើងអ្នកស្រែបាទ

ក៖ អូ!!បាទចុះសំរាប់ស្គាល់យាយនៅពេលណា
ហើយតាស្គាល់យាយបានប៉ុន្មានឆ្នាំដែរបានតាចូលស្ដីដណ្ដឹងយាយដែរ?

ខ៖ អូ!!បើនិយាយស្គាល់នឹងតាំងពីកើតមកនឹងស្គាល់គ្នារហូតដែរនឹងហាសកូន

ក៖ អូ!!ដោយសារតែនៅភូមិតែមួយហោសតា?

ខ៖ ពីមុននឹងភូមិនឹងវាមានពីរ ភូមិទួល នឹងភូមិត្រាចក្រោល
ប៉ុន្តែមកដល់ពេលបច្ចុប្បន្នឥឡូវនឹងគេហៅភូមិតែមួយនឹង

ក៖ អូ!!គេហៅភូមិទួលទៅ?

ខ៖ បាទចុះបើវាជាប់គ្នាមួយនៅខាងនេះ មួយទៀតនៅខាងនោះ

ក៖ អូ!!បាទតាបាទ?

ខ៖ ចឹងវាស្គាល់គ្នាតាំងពីតូចៗដែរទេនឹង

ក៖ ប៉ុន្តែតារៀនបានថ្នាក់ទីប៉ុន្មានដែរតា?

ខ៖ ខ្ញុំរៀនកាលពីជំនាន់ណុងខ្ញុំរៀនបានថ្នាក់ទី3នឹង

ក៖ អូ!!ចឹងហោសតា?

ខ៖ ចឹងវារៀនបានតិចណាស់

ក៖ អូ!! ប៉ុន្តែកាលពីតារៀននឹងតារៀននៅណាដែរតា?

ខ៖ ខ្ញុំរៀននៅសាលាយើងត្រពាំងអំពិលនឹង

កៈ អូ!!ប៉ុន្តែតាមានស្គាល់ឈ្មោះសាលាដែរទេ សាលាមានឈ្មោះអីគេដែរតា?

ខៈ សាលានឹងមានឈ្មោះថាសាលាវត្តត្រពាំងអំពិលនឹងតែម្តងនឹង

កៈ អូ!!វត្តត្រពាំងអំពិលណោះតា?

ខៈ បាទនឹងហើយ

កៈ ចុះដូចជាតាមានដូចជាមានចេះភាសាអីក្រៅពីភាសាខ្មែរយើងដែរទេ?

ខៈ អត់ទេអត់ចេះទេ

កៈ ដូចជាភាសាអង់គ្លេស ចិន ថៃ អត់ចេះដែរ?

ខៈ អត់មានចេះទេ

កៈ អូ!!បាទតា ចុះតាធ្លាប់មានមិត្តភក្តិតាំងពីក្មេងរហូតមកដល់ពេលនេះដែរទេតា មិត្តភក្តិជិតស្និទ្ធិរបស់តាហាស?

ខៈ វាអត់ទេ ដូចជាអត់ទេឥឡូវនឹងស្លាប់អស់ហើយនឹង

កៈ អូ!!ចឹងហោសតា?

ខៈ វាមាននៅមួយ នៅមួយនឹងប៉ុន្តែគ្រាន់តែថា អានឹងមិត្តភក្តិធ្វើទាហ៊ាននៅជំនាន់យើងឆ្នាំ1970នឹង

កៈ អូ!!ចឹងហោសតា?

ខៈ នៅឆ្នាំ1970នឹងចូលធ្វើជាទាហ៊ាន ហើយដល់ពេលដែរធ្វើទាហ៊ាននៅជាមួយគ្នាទៅ យើងស្គាល់គ្នារាប់អានគ្នារហូតទាល់តែបែកគ្នានៅឆ្នាំ1975នឹង

កៈ អូ!!បាទតាបាទ?

ខៈ ដល់ពេលដែរបែកនៅឆ្នាំ1975នឹង រហូតទាល់តែយើងចូលឆ្នាំវៀតណាមរំដោះយើផងចេញមកនឹង ក៏បានមកជួបគ្នាវិញចឹងមកនឹង

កៈ អូ!!ប៉ុន្តែគាត់មានឈ្មោះអីគេដែរតា?

ខ៖ អើរ ឈ្មោះគេជំនាន់ណុងគេមិនដឹងថាឈ្មោះអីទេ ប៉ុន្តែគេហៅតែវ៉ានៗៗចឹងតែម្តងនឹងហាស

ក៖ អូ៎!!ហៅតាវ៉ានណាតា?

ខ៖ មិនដឹងថាស្អីវ៉ានទេ

ក៖ ប៉ុន្តែតាគិតថាតាធ្លាប់មានអនុស្សាវរីយ៍អីធ្លាប់ដើរអី រឺមួយក៏នៅក្នុងជំនាន់ពលពតនឹង ធ្លាប់មានបញ្ហាអីជាមួយគ្នា រឺមួយក៏សប្បាយអីជាមួយក្នាចឹងហាសណាស់តា?

ខ៖ អត់មានទេ ធ្លាប់ជំនាន់ពលពតនឹងបែកគ្នា

ក៖ អូ៎!!បាទតាបាទ?

ខ៖ ប៉ុន្តែអាយើងនៅសម័យលុនណុលអាសម័យតាំងពីឆ្នាំ1970

ក៖ មុនពលពតទៀតណាតា?

ខ៖ ឆ្នាំ1970-1975នឹង

ក៖ អូ៎!!បាទតានឹង?

ខ៖ អានឹងធ្វើជាទាហ៊ាននៅជាមួយគ្នា

ក៖ អូ៎!!ប៉ុន្តែតាធ្លាប់មានអនុស្សាវរីយ៍អីទេ?

ខ៖ ដល់ពេលដែរបានមកយើងរំដោះនឹង អាពតគេរំដោះចូលអាពតគេកាន់កាប់មក បែកគ្នាតាំងពីនឹងមករហូតនឹង

ក៖ អូ៎!!ប៉ុន្តែ តាធ្លាប់មានអនុស្សាវរីយ៍អីជាមួយគាត់ដែរទេ?

ខ៖ ធ្លាប់មានអនុស្សាវរីយ៍ធ្លាប់ដើរឡើង ដើរបាញ់អីនឹងវា លក្ខណហះថាវាមានបញ្ហាអីយើងជួយគ្នាទៅ វិញទៅមកនឹងហាស

ក៖ បាទតា ចុះតាគិតថាតាធ្លាប់ធ្វើការងារអីគេខ្លះដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសតា?

ខ៖ បើនិយាយពីការធ្វើការតាំងពីក្មេងរហូតមកដល់ពេលនេះខ្ញុំ
រឿងការងាររាជ្យការអីនឹងខ្ញុំ មិនដែរបានធ្វើអីនឹងគេដែរទេនឹង

ក៖ អូ៎!!បាទតាបាទ?

ខ៖ បើយើងធ្វើជាទាហ៊ានវិញយើងធ្វើតែទាហ៊ាននៅឆ្នាំ1970-1975នឹងហាស

ក៖ បាទតាបាទនឹង?

ខ៖ ចឹងអស់រយះពេល5ឆ្នាំហើយនឹង

ក៖ បាទតាបាទនឹង?

ខ៖ អានឹងចូលធ្វើជាទាហ៊ាននឹង

ក៖ ចុះតាគិតថា?

ខ៖ តែបើនៅពីក្មេងនឹងអត់មានរកអីគេដែរទេ រកស៊ីចិញ្ចឹមតែប្អូននឹង

ក៖ បាទតាបាទ?

ខ៖ ឡើងត្នោតទៅក៏ឡើង អាកាប់អូសឡុក ក៏កាប់ដែរដើម្បីចិញ្ចឹមជីវិត

ក៖ អូ៎!!ចឹងតាធ្វើច្រើនណាតា?

ខ៖ បាទចឹងវាជួបប្រទះច្រើនដែរនឹងរឿងលំបាកនឹង

ក៖ បាទតា ចុះតាគិតថាតាធ្លាប់ធ្វើស្រែចំការដែរទេ?

ខ៖ ស្រែចំការនឹងធ្វើ

ក៖ អូ៎!!តាធ្វើហោស ពេលណុងតាធ្វើអីគេខ្លះដែរទៅនៅស្រែចំការនឹងហាស?

ខ៖ ស្រែចំការមានអីមានតែការស្ទូង នឹងដក ភ្ជួរ រាស់នឹងដក ស្ទូងនឹងហាស

ក៖ បាទតា ចឹងហោស?

ខ៖ ហើយធ្វើចំការ ដាំពោត ដាំបន្លែអីចឹងទៅ

ក៖ បាទតា ចុះតាគិតថាតាមានធ្លាប់ចិញ្ចឹមសត្វ ចិញ្ចឹមមាន់ ទា គោ ក្របីអីគេដែរទេ?

ខ៖  គោ ក្របី អារឿងគោ ក្របីនឹងយើងចិញ្ចឹមវាជាធម្មតាអីនឹង

ក៖  បាទតាបាទ?

ខ៖  បើអាចិញ្ចឹមជាលក្ខណៈធំដុំអីនឹងអត់ដែរមានទេអាអូន

ក៖  អូ៎!!ចឹងហោសតា?

ខ៖  ចិញ្ចឹមតាលក្ខណៈគ្រួសារនឹងចិញ្ចឹមតិចតួចអីនឹង
បើថាអោយបើកជាការដ្ឋានអីនឹងអត់ដែរមានទេ

ក៖  បាទអូចឹងទេហោសតា ចុះ?

ខ៖  តែបើយើងចិញ្ចឹមតាមផ្ទះតាមអីចឹងនឹងវាមាន

ក៖  អានឹងវាមាននរណាតា?

ខ៖  បាទនឹងមាន

ក៖  ចុះសំរាប់តា?

ខ៖  គោមាន4-5ក្បាលអីចឹងទៅវាមាន

ក៖  ចុះសំរាប់តាគិតថាជីវិតរបស់តានឹងមានការផ្លាស់ប្តូរអីគេខ្លះដែរទៅតា?

ខ៖  ដូចជាអត់មានអីផ្លាស់ប្តូរអីដែរនឹងហាស

ក៖  ចឹងនៅតែដដែរទេណតា?

ខ៖  បាទនៅសម័យនោះ គិតមកខ្ញុំចូលធ្វើមេភូមិនឹងតាំងពីឆ្នាំ1970នឹង

ក៖  បាទតា ចុះតាគិតថាតាចូលចិត្តពិសារម្ហូបអីគេដែរតា?

ខ៖  អូ៎!!ម្ហូបខ្ញុំអីក៏ត្រូវដែរខ្ញុំអត់ចេះខុសទេ

ក៖  ចឹងតាហូបទាំងអស់ណតា?

ខ៖  បាទរឿងម្ហូបនឹងខ្ញុំអត់ចេះទាស់គេតែម្តងនឹងហាស

ក៖  អូ៎!!ចឹងហោសតា?

ខ៖ ម្ហូបអីក៏ខ្ញុំហូបកើតដែរនឹង

ក៖ ចុះតាគិតថាតាំងពីក្មេងនឹងតាធ្លាប់បានលេងល្បែងប្រជាប្រិយ៍អីគេដែរទេតា?

ខ៖ អូ៎!!ពីដើមនឹងធ្លាប់មិនមែនថាមិនធ្លាប់ទេ

ក៖ លេងលក្ខណះថាចោលឈូង?

ខ៖ កាលពីដើមនឹងលេងចោលឈូង

ក៖ បោះអង្គុញ ទាញព្រាតអីហាសណាតា?

ខ៖ បោះអង្គុញអីនឹង ទាញព្រាតអីនឹងទាញអីនឹងដែរនឹង

ក៖ អូ៎!!បាទៗៗតា?

ខ៖ ចុះកាលពីនៅក្មេងនឹងធ្លាប់ប្រឡូកចូលក្នុងការ ផឹកស៊ីនឹងក៏វាមានច្រើនដែរនឹង

ក៖ ចុះសំរាប់តាគិតថាតាចូលចិត្តច្រៀងដែរទេ?

ខ៖ អត់ចូលចិត្តទេ

ក៖ ប៉ុន្តែតាចូលចិត្តស្ដាប់បទចំរៀងដែរទេ?

ខ៖ នឹងចូលចិត្តស្ដាប់ដែរនឹង

ក៖ ប៉ុន្តែលក្ខណះបទបុរាណ រឺមួយក៏បទសម័យដែរតា?

ខ៖ បទបុរាណយើងពីដើមៗនឹងហាស

ក៖ អូ៎!!បាទតា
ចុះតាគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់តាចេះលេងឧបករណ៍ភ្លេងដែរទេមានទេតា?

ខ៖ អត់អត់មានទេគ្រួសាររបស់ខ្ញុំនឹងមានតែឪពុករបស់ខ្ញុំតែម្ដងនឹង

ក៖ អូ៎!!បាទតាបាទនឹង?

ខ៖ គាត់ជាអ្នកលេងភ្លេងទេនឹង

កៈ ចុះគាត់ចេះលេងអីគេដែរតា?

ខៈ ឪពុករបស់ខ្ញុំនឹងភ្លេងអីក៏គាត់លេងកើតដែរនឹង

កៈ អូ៎!!បាទតា ចុះ?

ខៈ តាំងពីផភ្លេងសាម៉ុត ភ្លេងការ ភ្លេងរាំវង្ស រាំអីនឹងហាស

កៈ អូ៎!!គាត់ចេះទាំងអស់ហោសតា?

ខៈ បាទគាត់ចេះលេង

កៈ បាទតា ចុះតាគិតថាផ្ទះរបស់តានឹងមានលក្ខណៈបែបណាដែរតា តាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ ផ្ទះរបស់ខ្ញុំនឹងពីដើមនឹងផ្ទះខ្ពស់ធំដែរនឹង

កៈ អូ៎!!ចុះផ្ទះណុងនរណាគេជាអ្នកសាងសងដែរតា?

ខៈ ផ្ទះនឹងឪពុករបស់ខ្ញុំនឹង

កៈ អូ៎!!គាត់ចេះធ្វើផ្ទះ?

ខៈ គាត់ធ្វើផ្ទះកាលពីជំនាន់ណុង គាត់ធ្វើនៅខ្លួនគាត់នឹងហាស

កៈ ប៉ុន្តែតាចេះធ្វើផ្ទះទេតា?

ខៈ ផ្ទះនឹងវា ខ្ញុំអត់ចេះធ្វើទេប៉ុន្តែគ្រាន់តែ ផ្ទះតូចតាច់អីនឹងយើងអាចធ្វើបាន

កៈ អូ៎!!ចឹងហោសតា?

ខៈ ប៉ុន្តែផ្ទះធំអីនឹងធ្វើអត់បានទេ

កៈ អូ៎!!បាទចុះតា?

ខៈ ប៉ុន្តែបើផ្ទះតៀមអីចឹងៗខ្ញុំអាចធ្វើកើតនឹង

កៈ អូ៎!!ចឹងហោសតា?

ខៈ បាទនឹងហើយចឹង

កៈ ចុះតាគិតថាតាមានជំនាញអីដែរតាចេះស្នាត់ជំនាញតែម្តងដែរតាគិតថាតាចេះហាស?

ខៈ ទេជំនាញអីពិតប្រាកដនឹងក៏មិនដឹងថា

កៈ មានអីពិតប្រាកដដែរ?

ខៈ មិនមានដឹងថាអីពិតប្រាកដទេអូនអើយ ប៉ះអីធ្វើនឹងប៉ះអីធ្វើនឹង

កៈ បាទតា
ចុះតាគិតថាឪពុកម្តាយរបស់តានឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅតាដែរទេ
ដូចលក្ខណៈថាក្ងរស្គរត្មោត វេញវល្លិ៍ ធ្វើផ្តៅ រឺមួយធ្វើជាកន្ទេលអីចឹងហាស?

ខៈ ទាំងអស់នឹងចេះអូន

កៈ អូ៎!!តាចេះហោសតា?

ខៈ បាទនឹងហើយចេះ

កៈ ចុះនរណាគេដែរបង្រៀនតានឹង?

ខៈ អើរនឹងគឺតាមឪពុកនឹងឃើញគាត់ធ្វើចឹងទៅ ចេះតែធ្វើតាមគាត់ចឹងទៅ

កៈ បាទបាទនឹងតា?

ខៈ វេញខ្សែ ធ្វើត្នោតធ្វើអី ឡើងត្នោតឡើងអីនឹងខ្ញុំចេះ

កៈ បាទតាចុះតាគិតថា តាមានការលំបាកអីពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ វាដូចជាខ្ញុំបានជំរាប់ខាងដើមចឹងកាលពីក្មេងនឹងយើងជាបងទី3ម្ល៉ោះហើយនឹង
ប្អូននឹងវានៅតូចៗនឹងហើយការរកស៊ីចិញ្ចឹមប្អូននឹងវាមានផលលំបាកច្រើន
ដូចខ្ញុំថាចឹងនៅពីក្មេងនឹងហាស

កៈ បាទតាបាទ?

ខៈ រហូតបានមិនបានទៅរៀនសូត្រដោយសារតែស្អីដោយសារតែចឹងហាសចិញ្ចឹមប្អូន

កៈ ចុះកាលពីជំនាន់ពលពតនឹងតាគិតថាតាមានការលំបាកអីគេខ្លះដែរទៅតា?

ខៈ អូ៎!!បើនិយាយពីសម័យពលពតនឹងលំបាកនោះវាវេទនាហួសហើយនឹងហាស

កៈ អ៊ូ!!បាទតាបាទ?

ខៈ វាហួសពីការស្មានហើយនឹងបើនិយាយរឿងពលពតវិញនឹង

កៈ ប៉ុន្តែពេលណុងគេជំលាសតាទៅណាទេ?

ខៈ មួយថ្ងៃៗៗគេបង្អត់បាយយើងហើយគេអោយធ្វើការងារទល់ព្រលប់ទៀតហោស

កៈ ប៉ុន្តែពេលណុងគេជំលាសតាទៅណាដែរទៅតា?

ខៈ គេជំលាសខ្ញុំទៅនៅត្រពាំងចូរ

កៈ អ៊ូ!!ចឹងហោសតា?

ខៈ គេយកទៅដាក់ធ្វើឆ្លីយសឹកនឹង គេដាក់យើងជាឆ្លីយសឹកនៅត្រពាំងចូរ

កៈ ប៉ុន្តែតាពេលណុងតាអាយុប៉ុន្មានឆ្នាំដែរតា?

ខៈ ពេលដែរខ្ញុំនៅជាប់ឆ្លីយសឹកនឹងខ្ញុំនៅអាយុជាង20ឆ្នាំ

កៈ អ៊ូ!!ចឹងតានៅកងចល័តហើយណតា?

ខៈ បាទនឹងហើយ

កៈ ប៉ុន្តែគេអោយធ្វើអីគេខ្លះដែរទៅតា?

ខៈ គេអោយលើកទំនុប គេអោយជីកប្រឡាយ កាប់គាស់កាប់ព្រៃ

កៈ អ៊ូ!!ចឹងហោសតា?

ខៈ យើងថាពេលណុងគេលុត្តមយើងហើយនឹងគេអោយយើងជីកប្រឡាយជីកអីចឹងទៅ

កៈ បាទតាបាទនឹងហើយ?

ខៈ
បើនិយាយពីស្នាដៃនឹងនៅរហូតនឹងនៅពាមល្វានៅខេត្តណាក៏ខ្ញុំនៅដែរនៅទំនុបពាមល្វានឹងហាស នៅទំនុបពាមល្វាយើងត្រពាំងចុរនឹង

កៈ អ៊ូ!!បាទតាបាទ ចឹងមានបញ្ហាច្រើនណតា?

ខ៖  បាទ‼ខ្ញុំមួយថ្ងៃមួយថ្ងៃនឹង
យើងមិនបានរំពឹងថាយើងបានរស់រានមានជីវិតដែរទេផងនឹង
ទាល់តែសព្វថ្ងៃនឹងជំនាន់ណុងបើវាអោយការងារយើងធ្វើច្រើន
ហើយការហូបនឹងបានហូបតិច

ក៖  ដូចជាកាលណុងគេហូបអីគេដែរតា?

ខ៖  គេអោយយើងហូបបាយហូបបបរយើងធម្មតានឹង
ប៉ុន្តែគ្រាន់តែមិនអោយយើងហូបបានច្រើនឹងហាស

ក៖  គេមិនអោយហូបបានច្រើនហោសតា?

ខ៖  បាទនឹងវាចឹង

ក៖
ប៉ុន្តែពេលណុងដូចជាជំលាសទៅជាក្រុមគ្រួសារវីមួយក៏ជំលាសតាទៅតែម្នាក់ឯងទេតា?

ខ៖  ខ្ញុំជំលាសទៅតែម្នាក់ឯងនឹង

ក៖  អូ៎‼ចឹងហោសតា?

ខ៖  ក្រុមគ្រួសារនឹងបែកគ្នានឹង

ក៖  បាទតាបាទនឹង?

ខ៖
គ្រួសាររបស់ខ្ញុំបានបែកគ្នាហើយបានជួបគ្នានៅឆ្នាំយើងឆ្នាំ1979យើងនឹងវិញនឹងហាស

ក៖  អូ៎‼ទាល់តែដាច់អាពតនឹងយើងបានជួបគ្នាវិញហោសតា?

ខ៖  បាទ‼វៀតណាមចូលរំដោះវិញមកនឹង

ក៖  អូ៎‼បាទតា ចុះតាគិតថាតាំងពីដាច់ពលពតនឹង
ចូលឆ្នាំប៉ែតជាងនឹងតាមានការលំបាកអីគេដែរតា?

ខ៖  នៅឆ្នាំប៉ែតជាង

កៈ ដូចថាទាំងកំឡុងពេលប៉ែតជាងហាស
ដូចជាតាមានការលំបាកដូចជាតាត្រូវការរកលុយហើយណា
ពេលណុងគេចាយលុយហើយណាតា?

ខៈ បាទៗៗ!!នឹងហើយ

កៈ ចឹងតាមានការលំបាកអីគេដែររកស៊ី?

ខៈ ពីព្រោះវាមានផលលំបាកច្រើនដែរពេលដែរបានជួបជុំក្រុមគ្រួសារវិញនឹងហាស
ទី1នឹងយើងទើបតែ រំដោះចេញពីអាពត ណាមួយធ្វើការជារួចផងនឹង

កៈ បាទតាបាទ?

ខៈ ចឹងជំនាន់យើងរំដោះចេញមកមុនបានប៉ុន្មានឆ្នាំនឹងយើងធ្វើការគិតមើលធ្វើស្រែជារូម
ម៉្លោះហើយយើងចែកគ្នាទៅតាមកំលាំង

កៈ បាទតាបាទនឹង?

ខៈ មានកំលាំងទីមួយ មានកំលាំងទីពីរចឹងទៅទទួលផលបានប៉ុន្មានៗៗអីចឹងទៅ

កៈ បាទតាបាទនឹង?

ខៈ ចឹងយើងវាមានផលលំបាកច្រើនដែរនឹងហាស

កៈ អូ៎!!ចឹងហោសតារហូតដល់?

ខៈ ណាមួយខ្លួចហូបចុកវាអត់គ្រប់គ្រាន់នឹង ហើយបញ្ហាទីពីរនឹងបញ្ហាក៏
វាមានខ្មែរក្រហមនៅខាងក្រៅទៀតនឹង

កៈ បាទតាបាទ ចុះ?

ខៈ យើងអ្នកធ្វើការ ចុះកាលណុងយើងចុះមកយើងគ្រប់គ្រងប្រជាពលរដ្ឋ

កៈ អូ៎!!ចឹងហោសតា ចុះតាគិតថានៅឆ្នាំណាដែរតាគិតថាសន្តិភាពហើយស្រួលហាសតា
បានស្រួលរកស៊ីអីចឹងហាស?

ខៈ យើញបានមករកស៊ីស្រួលនឹងនៅកន្លែងយើងឆ្នាំ

កៈ នៅឆ្នាំកៅជាងហីតា?

ខៈ បាទនៅឆ្នាំកៅជាងនឹងហើយ នៅឆ្នាំ1991-1992នឹងហាស

កៈ នៅពេលដែរសម្តេចចូលមកគ្រងរាជ្យវិញហើយណាតា?

ខៈ នឹងហើយនៅពេលដែរសម្តេចចូលមកគ្រងរាជ្យវិញនឹងហាស
នៅពេលគាត់យាងចូលមកនៅ

កៈ ចូលមកគ្រងរាជ្យនឹង?

ខៈ មកប្រទេសកម្ពុជាយើងវិញនឹងហាស

កៈ បាទតាបាទនឹង?

ខៈ បានអាពតចេញផុតអស់នឹងចូលមកយើងមកអស់នឹងអានឹងវារៀងដូចជាគ្រាន់ធូរ

កៈ អានឹងយើងអាចរកស៊ីស្រួលហើយណាតា?

ខៈ នឹងហើយយើងអាចរកស៊ីស្រួលតាមនរណាគេមានកំលាំងរកទៅ
គេមានចំនេះរកទៅគេរកបានចឹងទៅណាស់

កៈ តាមអ្វីដែរគេខិតខំប្រឹងប្រែងនឹងទៅ?

ខៈ នឹងហើយត្រូវតែចឹង

កៈ ចុះតាគិតថា?

ខៈ មានជំនាញអីគេរកស៊ីរបស់គេទៅនិងគេរកស៊ីបានរបស់គេនឹង

កៈ បាទតាបាទ?

ខៈ ប៉ុន្តែជំពោះខ្ញុំនៅតែការគ្រប់គ្រងរបស់ភូមិនៅតែ

កៈ នៅតែធ្វើចឹងហោសតា?

ខៈ នៅតែធ្វើនៅការគ្រប់គ្រងរបស់ភូមិចឹងហាស

កៈ បាទតាបាទ?

ខ៖  ចឹងវាការរកស៊ីវាអត់បានមកគ្រាន់តែរៀបការអោយកូនចៅនឹងអស់ទៅវិញហើយនឹង

ក៖  អ៎ូ!!បាទតាបាទ?

ខ៖ ថាអោយបានទុកដាក់អីអត់មានទេ

ក៖  បាទចុះតា?

ខ៖ ទាល់តែនៅសព្វថ្ងៃនេះនៅតែ ធម្មតាវាមិនជាអត់ពេកហើយក៏វាមិនមានពេក

ក៖  វាក៏មិនមានពេកវាលក្ខណៈធម្មតាហើយណតា?

ខ៖  បាទវាធម្មតានឹងហាស

ក៖  បាទតាបាទចុះតា?

ខ៖  វាជាមនុស្សធម្មតា ហើយញ្ញាតិមិត្តទទួលស្គាល់យើងរាប់អានយើងធម្មតាចឹងទៅ

ក៖  បាទតាចុះតាគិតថាតាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរតា?

ខ៖  ហ៎ា!!អាបញ្ហាឆ្លងកាត់ការលំបាកនេះ
ទាល់តែយើងអត់ធ្មត់ណាស់ទាល់តែយើងអត់ធ្មត់ណាស់នឹង

ក៖  បាទតាបាទ?

ខ៖  ថាធ្វើចិត្តយើងធ្វើម៉េចតាំងចិត្តយើង

ក៖  អោយពុះពារឧបសគ្គហោសតា?

ខ៖  នឹងហើយជំនះឧបសគ្គច្រើន ចឹងបើយើងបណ្តោលទៅតាមឧបសគ្គច្រើននឹង
បើយើងមិនមានការទប់ស្កាត់នឹងក៏មិនកើតដែរនឹង

ក៖  បាទតាបាទ?

ខ៖
បាទជំនាន់ណុងពីព្រោះវាដូចយលងដឹងស្រាប់ហើយប្រទេសយើងនឹងវាមានជនខឹលខូច
ច្រើន អ្នកខ្លះភ្លើតភ្លើនទៅមានបក្សពួកអីច្រើនទៅអាចមាន
បក្សពួកអូសទាញទៅអាចមានបញ្ហាលំបាក ដល់ខ្លួនក៏មានដែរនឹង

កៈ ចឹងយើងអត់ដឹងទេណាតា?

ខៈ បាទចឹង
ខ្ញុំបានណែនាំទាំងប្រជាពលរដ្ឋទាំងរូបខ្ញុំផ្ទាល់នឹងថាធ្វើម៉េចកុំអោយចិត្តយើងនឹងភ្លើតភ្លើនទៅតាមការអូសទាញរបស់ពួកគេនឹង

កៈ បាទតាបាទនឹង?

ខៈ កាលពីជំនាន់ណុងវាមានអ្នកអូសទាញវាច្រើនដែរនឹងហាស

កៈ អូ៎!!នឹងតា?

ខៈ ខ្លះទាញចេះខ្លះទាញចុះនឹង

កៈ អូ៎!!ចឹងហោសតា?

ខៈ
ចឹងអាបញ្ហាអ្នកដែរទៅតាមនឹងវាសុទ្ធតែមានបញ្ហាអាខ្លះនឹងមកទល់ថ្ងៃនេះនឹងមិនទាន់បានឃើញ មកនៅស្រុកវិញផងនឹង

កៈ អូ៎!!ចឹងហោសតា ចុះតាគិតថា?

ខៈ ចឹងវាមានផលលំបាកច្រើនដែរនឹង

កៈ ចុះតាគិតថាពេលដែរតាសប្បាយហាស
ពេលដែរតាសប្បាយហើយតើពេលណាដែរតា?

ខៈ ពេលដែរខ្ញុំសប្បាយនិយាយអោយត្រង់ទៅពេលដែរអស់មានពួកក្បត់នៅខាងក្រៅនឹងមានការចូលមករំដោះជាតិ ចូលមកនឹងមានការសប្បាយរហូតតាំងពីណុងមកនឹង

កៈ អូ៎!!បាទតាបាទ?

ខៈ តាំងពីឆ្នាំ1992-1993នឹងមកនឹង

កៈ ចឹងសប្បាយហើយនៅពេលណុងណាតា?

ខៈ បាទនឹងហើយសប្បាយតែគ្រាន់តែការរកស៊ីរបស់យើងនៅជាធម្មតានឹង

កៈ អូ៎!!ចឹងហោសតា?

ខៈ ប៉ុន្តែគ្រាន់តែការសប្បាយដែរយើងដើរហើរតាមចិត្តយើងចង់ទៅណាក៏បានដែរ ធ្វើអីក៏បានដែរអានឹងវាតែងតែមានការសប្បាយចិត្តទល់នឹងបច្ចុប្បន្ននឹង

កៈ បាទតា
ចុះតាកាលពីក្មេងនឹងតាធ្លាប់មានគោលបំណងថាតាធំឡើងនឹងតាចង់ធ្វើអីគេមួយដែរទេ លក្ខណៈគ្រូពេទ្យ គ្រូបង្រៀនអីចឹងហាសតា?

ខៈ អត់ដែរមានបំណងអីសោះអូន

កៈ អូ៎!!ចឹងហោសតា?

ខៈ ចុះកាលពីក្មេងនឹងគ្មានបំណងចុះយើងជាកូនកសិករនឹង
យើងមានតែបំណងធ្វើតែស្រែហ្វបនឹងតែម្តងនឹងហាស

កៈ អូ៎!!ចឹងចិត្តចង់ធ្វើតែស្រែទេណាតា?

ខៈ អានឹងលក្ខណះថាវាយើងគ្មានបំណងអីនៅសម័យយើងឆ្នាំប៉ែតជាង
នៅឆ្នាំកៅសិបជាងគេអោយ យើងទៅធ្វើការងារឡើងទៅនៅស្រុកអីនឹងអត់ចង់ទៅផងនឹង

កៈ អូ៎!!ចឹងហោសតា?

ខៈ ចង់តែនៅភូមិនឹងចង់តែធ្វើស្រែហ្វបនឹងតែម្តងនឹង

កៈ បាទតាបាទចុះ?

ខៈ មានដែរតើពេលដែរយើងទៅធ្វើការទៅគេហៅទៅដែរនឹង
ហៅអោយយើងទៅធ្វើការងារនៅស្រុក ហៅអោយអីចឹងយើងមិនព្រមទៅនឹង

កៈ អូ៎!!បាទតាបាទចុះ?

ខៈ នេះគេមានមិត្តភក្តិមានអីគេហៅចឹងដែរនឹងហាស

កៈ បាទតាបាទល្អតា?

ខៈ តែយើងវាមិនទៅនឹង

កៈ ចុះតា?

ខៈ ខ្ញុំថាហេអញ់សុខចិត្តនៅធ្វើស្រែស៊ីវិញហើយនឹង

កៈ ចុះបើសិនជាចង់អោយតាផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗ
តើតាចង់ផ្តែផ្តាំអីទៅពួកគាត់ដែរដើម្បីអោយគាត់នឹងអាចធ្វើតាមគំរូតាចឹងហាស?

ខៈ បាទពីព្រោះអានេះយើងមិនអាចបង្ខំបានទៅលើចំណូលចំណង់ចិត្តរបស់គេណាស់

កៈ បាទតាបាទ?

ខៈ
ប៉ុន្តែគ្រាន់តែយើងមានការផ្តែផ្តាំដែរថាធ្វើម៉េចកូនចៅទាំងអស់ធ្វើម៉េចអោយវាដើរតាមសង្គមរបស់គេ

កៈ បាទតាបាទនឹង?

ខៈ ធ្វើម៉េចកុំអោយតែវាមានបញ្ហានៅក្នុងសង្គមទៅបានហើយនឹង

កៈ បាទតាបាទ?

ខៈ ទោះបីតែការងារអានឹងទាល់តែគេចិត្តគេចង់ខ្លួនគេផងនឹង
បើចិត្តគេមិនចង់នឹងក៏មិនអាចធ្វើការងារ អីបានដែរនឹងហាស

កៈ ត្រូវហើយតានឹង

ខៈ អ្វីហាមដាច់ខាតអោយតែដើរតាមសង្គមរបស់គេទៅ

កៈ ចុះបើសិនជាលក្ខណះថាបង់អោយពយកគាត់ជៀសវៀងវិញ
តើតាចង់អោយពួកគាត់ជៀសវៀងអីគេដែរតា?

ខៈ ជៀសវៀងអ្វីក៏ដោយដែរវាក្បត់នឹងឆន្ទះនឹងប្រទេសជាតិអត់ចង់អោយមានតែម្តងនឹង

កៈ អ៊ូ!!ចឹងហោសតា?

ខៈ បាទគោលបំណងរបស់ខ្ញុំធ្វើម៉េចអោយដើរទៅតាមសង្គមរបស់គេទៅតាម

កៈ ចុះសំរាប់ក្មេងជំនាន់ក្រោយតាគិតថាចង់អោយគាត់ជៀសពីជក់គ្រឿងញៀន?

ខ៖ នឹងហើយចង់អោយតែវាជៀសវៀងពីបញ្ហាណាមួយដែរវាទំនាស់នឹងជាតិ

ក៖ អ៊ូ!!បាទតាបាទនឹង?

ខ៖ នឹងគោលនយោបាយរបស់រដ្ឋាភិបាល

ក៖ បាទតាបាទនឹង?

ខ៖ ខ្ញុំចង់អោយគេដើរតាមផ្លូវល្អ

ក៖
បាទតាចឹងជាចុងក្រោយខ្ញុំអរគុណច្រើនតាដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់តា ហើយការសំភាសន៍ទាំងអស់នេះ
ដើម្បីទុកតំកល់ទុកអោយកូនចៅរបស់តាបានដឹងចឹងហាសតា

ខ៖ បាទនឹងហើយ

ក៖ បាទអរគុណច្រើនតា៕៕៕